**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកសណ្ឋាគារ ហ្គាឌិន ស៊ីធី**
លេខបញ្ជីពាណិជកម្ម ៖០០០២៨៣៩១
លេខអត្តសញ្ញាណសហគ្រាស ប.ស.ស ៖ ១០០៩០៥៧ថ
អាស័យដ្ឋាន៖ #មហាវិថីវិមាន ឈ្នះ ឈ្នះភូមិព្រែកតាវ័ត្ន សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានី ភ្នំពេញ។

**សូមគោរពជូន**
**លោកប្រធាននាយកអធិការកិច្ចការងារ**

**កម្មវត្ថុ៖** សំណើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិកចំនួន៩២នាក់រយះពេល០២ខែ។
**យោង៖** មាត្រា៧១និងមាត្រា៧២នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា ដោយសារតែមានការផ្ទុះឡើងនូវជំងឺ កូវីត១៩ (Covid 19)ធ្វើអោយអតិថិជនរបស់ក្រុមហ៊ុនយើងខ្ញុំបានធ្វើការរលប់ចោលនូវកម្មវិធីប្រជុំផ្សេងៗនិងការកក់បន្ទប់ស្នាក់នៅដែលជាហេតុធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះក្រុមហ៊ុនយើងខ្ញុំ។ហេតុដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៩២នាក់ ក្នុងចំណោមកម្មករនិយោជិកសរុបចំនួន២០៨នាក់រយះពេល០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ខែឧសភាឆ្នាំ២០២០រហូតដល់ថ្ងៃទី៣០ខែមិថុនាឆ្នាំ២០២០។

ក្នុងអំឡុងពេលពេលនៃការព្យួរកិច្ចសន្យាការងារបុគ្គលិកចាប់ពីថ្ងៃទី០១ខែឧសភាឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ខែមិថុនាឆ្នាំ២០២០ក្រុមហ៊ុនសំរេចមិនផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិកឡើយ ដោយសារក្រុមហ៊ុនគ្មានចំណូលនឹងយោងការព្រមព្រៀងរវាងក្រុមហ៊ុននឹងប្រតិភូបុគ្គលិក។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកប្រធាន មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ខែមេសា ឆ្នាំ២០២០
ហត្ថលេខានាយកក្រុមហ៊ុន

GARDEN CITY HOTEL
HUMAN RESOURCES DEPARTMENT

ជូនភ្ជាប់មកជាមួយ៖
-កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជក
-វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចំលង)ចំនួន៣ច្បាប់
-បណ្ណពន្ធប៉ាតង់ច្បាប់(ថតចំលង)ចំនួន៣ច្បាប់
-វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុងប.ស.ស ចំនួន៣ច្បាប់

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## នាយកសណ្ឋាគារ ហ្គាឌិន ស៊ីធី
## កិច្ចព្រមព្រៀង

ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ នៅ **សណ្ឋាគារ ហ្គាឌិន ស៊ីធី** បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព លោក មាយ សុផា ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុនៃការផ្ទុះឡើងនូវជំងឺ កូវីត១៩ (Covid 19) ដែលជាហេតុធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះក្រុមហ៊ុនដោយធ្វើអោយអតិថិជនរបស់ក្រុមហ៊ុនការយើងធ្វើការលុបចោលកម្មវិធីប្រជុំផ្សេងៗ និងការកក់បន្ទប់ស្នាក់នៅ។

សមាសភាពចូលរួមៈ

១-ភាគីតំណាងក្រុមហ៊ុន

-លោក មាយ សុផា តំណាងអោយភាគីក្រុមហ៊ុន

-លោកស្រី ឌុក ស្រីរ័ត្ន ជំនួយការប្រធានផ្នែកធនធានមនុស្ស

-លោក ទូច សុខឡេង អ្នកកត់ត្រា

២-ភាគីតំណាងកម្មករនិយោជិក

-លោក ស្តើង លី ជាប្រតិភូបុគ្គលិក

-កញ្ញា ហុង ធាវី ជាប្រតិភូបុគ្គលិក

ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោមៈ

GARDEN CITY HOTEL
HUMAN RESOURCES DEPARTMENT

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន៩២នាក់ ដោយគិតចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២០រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារប្រតិភូបុគ្គលិកបានព្រមព្រៀងជាមួយនឹងក្រុមហ៊ុនដោយមិនផ្តល់ប្រាក់ឈ្នួលជូនក្នុងអំឡុងពេលព្យួរកិច្ចសន្យានេះឡើយដោយសារក្រុមហ៊ុនគ្មានប្រាក់ចំណូល។

៣-ចប់ការព្យួរការងារកម្មករនិយោជិតត្រូវមកធ្វើការងារនៅកន្លែងដើមវិញទៅតាមតួនាទីភារកិច្ចរបស់ខ្លួន។ ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៣:៣០នាទី នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសសប្បាយរីករាយ។

ថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២០ខែមេសា ឆ្នាំ២០២០

បានឃើញ និងឯកភាព
៥. តំណាងនាយកក្រុមហ៊ុន

GARDEN CITY HOTEL
HUMAN RESOURCES DEPARTMENT

បានឃើញ និងឯកភាព
តំណាងកម្មករនិយោជិត

-លោក ស្មើង លី ជាប្រតិភូបុគ្គលិក

-កញ្ញា ហ៊ុង ធារី ជាប្រតិភូបុគ្គលិក